N° 5

# សម្ភារៈអប់រំអ្នកបោះឆ្នោត

**សំណួរ:** **ក្នុងដំណើរការរៀបចំការបោះឆ្នោត គ.ជ.ប ក៏បានយកចិត្តទុកដាក់ក្នុងការផលិត និងផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត តើភារកិច្ចនេះ គ.ជ.ប ប្រគល់ជូននាយកដ្ឋានណាទទួលខុសត្រូវ ?**

**ចម្លើយ:** ភារកិច្ចនេះ គ.ជ.ប បានប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប ឱ្យទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត ។ (ប.ន ៧.១៣)

មិនតែប៉ុណ្ណោះ គ.ជ.ប ក៏បានអំពាវនាវ និងលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យចូលរួមយ៉ាងសកម្មក្នុងការផលិត និងផ្សព្វផ្សាយ ដើម្បីអប់រំ លើកកំពស់ការយល់ដឹងអំពីការបោះឆ្នោតជូនប្រជាពលរដ្ឋផងដែរ ។ (ប.ន ៧.១៣.១)

ដូច្នេះប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំអំពីការបោះឆ្នោត អាចទំនាក់ទំនងជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប ។ (ប.ន ៧.១៣.២)

**សំណួរ:** **តើសម្ភារៈអប់រំអ្នកបោះឆ្នោតទាំងឡាយ ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ គួរមានលក្ខណៈបែបណា ?**

**ចម្លើយ:** សម្ភារៈអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវមានលក្ខណៈអព្យាក្រឹត និងមិនលម្អៀង ។ សម្ភារៈទាំងនោះមិនត្រូវរៀបចំឡើងដើម្បីគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ហើយត្រូវគោរពទៅតាម ច.ប.ត.រ ប.ន.ត.រ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។ (ប.ន ៧.១៣.៣)

**សំណួរ:** **សម្ភារៈព័ត៌មានសាធារណៈ និងសម្ភារៈអប់រំអ្នកបោះឆ្នោតដែលផលិតដោយ គ.ជ.ប និងសម្ភារៈដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបានទទួលលិខិតយល់ព្រមពី គ.ជ.ប តើអាចកែប្រែបាន ឬ ទេ ?**

**ចម្លើយៈ** សម្ភារៈព័ត៌មានសាធារណៈ និងសម្ភារៈអប់រំអ្នកបោះឆ្នោតដែលផលិតដោយ គ.ជ.ប និងសម្ភារៈដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ហើយ មិនត្រូវបន្ថែម ឬបន្ថយខ្លឹមសារ ដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ ។ ដូច្នេះអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលបានសហការជាមួយ គ.ជ.ប ក្នុងការផលិតសម្ភារៈអប់រំអ្នកបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីមានការប្រព្រឹត្តខុសពីកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ។ (ប.ន ៧.១៣.៤)

**សំណួរៈ** **ដើម្បីធានាថា ខ្លឹមសារនៃសម្ភារៈអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ បានត្រឹមត្រូវតាម ច.ប.ត.រ ប.ន.ត.រ តើ គ.ជ.ប ត្រូវធ្វើដូចម្តេច ?**

**ចម្លើយៈ** ដើម្បីធានាថា ខ្លឹមសារនៃសម្ភារៈអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានរៀបចំត្រឹមត្រូវតាម ច.ប.ត.រ ប.ន.ត.រ និងបែបបទបច្ចេកទេស គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ ណែនាំ និងយល់ព្រម តាមការស្នើសុំរបស់អង្គការទាំងនោះ ។ (ប.ន ៧.១៣.៥)

ប៉ុន្តែ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ ឬយល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ ។ (ប.ន ៧.១៣.៦)

ទោះបីជាសម្ភារៈអប់រំត្រូវបានទទួល ឬមិនត្រូវបានទទួលការយល់ព្រមពី គ.ជ.ប ក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយ ត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយនឹងមិនត្រូវបានដាក់បន្ទុកឱ្យទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតលើខ្លឹមសារ បច្ចេកទេសនៃសម្ភារៈអប់រំទាំងនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ ។ (ប.ន ៧.១៣.៧)

**សំណួរៈ** **ក្នុងករណីដែលមានការស្នើសុំផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ តើអ្នកណាជាអ្នកទទួលភារកិច្ចនេះ ?**

**ចម្លើយៈ** ក្នុងករណីដែលមានការស្នើសុំផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពរបស់ គ.ជ.ប មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ ណែនាំ និងយល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីទទួលបានសំណើសុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់សម្ភារៈអប់រំនោះ ។ (ប.ន ៧.១៣.៨)

**សំណួរៈ** **ចុះបើក្នុងករណីដែលពិនិត្យឃើញថា សម្ភារៈ ឬខ្លឹមសារអប់រំនោះរៀបចំឡើងមិនសមស្របទៅតាម ច.ប.ត.រ ប.ន.ត.រ ទេ តើគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវធ្វើយ៉ាងណា ?**

**ចម្លើយៈ** ក្នុងករណីពិនិត្យឃើញថា សម្ភារៈ ឬខ្លឹមសារអប់រំត្រូវបានរៀបចំឡើងមិនសមស្របទៅតាម ច.ប.ត.រ និង ប.ន.ត.រ គណៈកម្មការនេះត្រូវបង្ហាញអំពីកំហុសឆ្គង ដែលត្រូវកែសម្រួល និងផ្តល់ព័ត៌មាន ទៅសាមីអ្នកស្នើសុំជាបន្ទាន់ តាមដែលអាចធ្វើបាន ។ (ប.ន ៧.១៣.៨)

**សំណួរៈ** **ចុះបើក្នុងករណីដែលការពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារៈអប់រំទាំងនោះហួសរយៈពេល ៧២ម៉ោង គណៈកម្មការនៅតែពុំទាន់បានឆ្លើយតបទៀត តើចាត់ទុកយ៉ាងណាទៅវិញ ?**

**ចម្លើយៈ** ក្នុងករណីគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ ហួសរយៈពេល ៧២ម៉ោង ដោយពុំបានផ្តល់ការឆ្លើយតបទេ ចាត់ទុកថាគណៈកម្មការនេះបានឯកភាពទាំងស្រុងលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន ។ (ប.ន ៧.១៣.៨)

**សំណួរៈ** **សម្ភារៈអប់រំអ្នកបោះឆ្នោតដែលត្រូវបានទទួលពិនិត្យ ផ្ទៀងផ្ទាត់ នោះមានសម្ភារៈបែបណាខ្លះ ?**

**ចម្លើយៈ** សម្ភារៈអប់រំអ្នកបោះឆ្នោតដែលអាចត្រូវបានទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប មានដូចជា ÷ (ប.ន ៧.១៣.៩)

- ស្ប៉តវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។ (ប.ន ៧.១៣.៩.១)
- ការស្បែតម៉ាញ៉េ ឬខ្សែអាត់សម្លេង ។ (ប.ន ៧.១៣.៩.២)
- ខិត្តប័ណ្ណផ្សេងៗ និងបដា ។ (ប.ន ៧.១៣.៩.៣)
- សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។ (ប.ន ៧.១៣.៩.៤)
- ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន ។ (ប.ន ៧.១៣.៩.៥)
- រូបភាព ឬពាក្យស្លោកបោះពុម្ពលើសំលៀកបំពាក់ ឬ មួក ។ (ប.ន ៧.១៣.៩.៦)

សម្ភារៈដែលត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខមួយច្បាប់សម្រាប់ជាឯកសារ ។ (ប.ន ៧.១៣.១០)

**សំណួរ:** **ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលស្ម័គ្រចិត្តរួមសហការជាមួយ គ.ជ.ប ក្នុងការផលិតសម្ភារៈអប់រំអ្នកបោះឆ្នោត ប៉ុន្តែគាត់មិនបានប្រើប្រាស់ប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់ទេ តើគាត់អាចជួបនឹងផលលំបាកយ៉ាងដូចម្តេចខ្លះ ?**

**ចម្លើយ:** អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យ ផ្ទៀងផ្ទាត់ ណែនាំ និងយល់ព្រមដែលផ្តល់ឱ្យដោយ គ.ជ.ប ត្រូវទទួលខុសត្រូវលើខ្លឹមសារ បច្ចេកទេសនៃសម្ភារៈអប់រំរបស់ខ្លួន តាមបញ្ញត្តិ ច.ប.ត.រ ។ ហើយប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារៈអប់រំដែលខ្លួនបានផលិតនោះ ត្រូវបានរកឃើញថា ពុំត្រឹមត្រូវតាម ច.ប.ត.រ និង ប.ន.ត.រ ឬមានភាពលម្អៀង ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ត.រ និង ប.ន.ត.រ គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារៈនោះទាំងស្រុងតែម្តង ។ (ប.ន ៧.១៣.១១)

**សំណួរ:** **តើសៀវភៅអប់រំអ្នកបោះឆ្នោតបែបណា ដែលអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ផលិតទៅមានលក្ខណៈត្រឹមត្រូវ ហើយដែល គ.ជ.ប អនុញ្ញាតឱ្យផលិតនោះ ?**

**ចម្លើយ:** អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោតដែលមានកម្មវិធីនយោបាយរបស់គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋាន មុនថ្ងៃចាប់ផ្តើមការឃោសនាបោះឆ្នោត និងអនុញ្ញាតឱ្យចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបាន តែក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោតប៉ុណ្ណោះ ។ (ប.ន ៧.១៣.១២)

**សំណួរ:** **ក្នុងករណីដែលអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា មានបំណងរៀបចំកម្មវិធីស្មើភាព ក្នុងប្រព័ន្ធផ្សព្វផ្សាយសម្រាប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត តើគាត់អាចធ្វើបានដែរឬទេ ?**

**ចម្លើយ:** គាត់អាចធ្វើបានក្នុងអំឡុងពេលឃោសនាបោះឆ្នោត ដោយអាចពិគ្រោះកម្មវិធីលំអិត និងធ្វើសហប្រតិបត្តិការជាមួយ គ.ជ.ប ។ (ប.ន ៧.១៣.១៣)

**សំណួរ:** **តើសកម្មភាពបែបណា ដែលត្រូវបានកំណត់ថាជាកម្មវិធីស្មើភាព ?**

**ចម្លើយ:** សកម្មភាពដែលត្រូវបានកំណត់ថាជាកម្មវិធីស្មើភាព មានដូចខាងក្រោម ÷

-កម្មវិធីមួយ ឬកម្មវិធីជាភាគ ដែលផ្តល់ឱកាសឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនីមួយៗ ផ្សព្វផ្សាយកម្មវិធីនយោបាយ ឬទស្សនៈនយោបាយ ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់ កិច្ចសម្ភាសន៍ ការពិភាក្សាសួរដេញដោល ការពិភាក្សាតុមូល វេទិកា ឬកម្មវិធីជជែកជាសាធារណៈ ដោយឈរលើមូលដ្ឋាននៃការផ្តល់ពេលវេលាស្មើភាពគ្នា ចំពោះអ្នកចូលរួមទាំងអស់ ។(ប.ន ៧.១៣.១៣.១)

-អនុលោមតាមមាត្រា ៧៤ នៃ ច.ប.ត.រ ដែលបានចែងថា គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមមានសារព័ត៌មាន វិទ្យុ និងទូរទស្សន៍របស់រដ្ឋ ត្រូវចុះផ្សាយគ្រប់ព័ត៌មានដែលស្នើឡើងដោយ គ.ជ.ប ដោយឥតយកថ្លៃ ដើម្បីផ្សព្វផ្សាយពីការងារបោះឆ្នោតនិងអប់រំដល់អ្នកបោះឆ្នោត។ ដូច្នេះដើម្បីសម្របសម្រួលឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនា តាមគោលការណ៍ស្មើភាព និងដើម្បីបញ្ចៀសបាតុភាព លុះត្រាតែរាល់សម្ភារៈអប់រំអ្នកបោះឆ្នោត និងសម្ភារៈឃោសនាដែលត្រូវបានផ្សព្វផ្សាយនោះជាទម្រង់អត្ថបទបោះពុម្ព ឬផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ មិនត្រូវប្រើប្រាស់រូបភាព ឬភាសាណាមួយដែលមានន័យ ញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬធ្វើឱ្យបាត់បង់ជំនឿលើភាពសម្ងាត់នៃការបោះឆ្នោត ឬសាបព្រួសភាពភ័យខ្លាចធ្វើឱ្យភ័ន្តច្រឡំ និងខូចសណ្តាប់ធ្នាប់សង្គម ឬក៏ផ្តល់ព័ត៌មានមិនត្រឹមត្រូវអំពីដំណើរការបោះឆ្នោត។ ដូច្នេះការផ្សព្វផ្សាយកម្មវិធីស្មើភាពនេះត្រូវមានលិខិតយល់ព្រមពី គ.ជ.ប ។

**សំណួរៈ** **តើ គ.ជ.ប មានសិទ្ធិបញ្ជាឱ្យផ្អាក ឬបញ្ឈប់ការផ្សព្វផ្សាយកម្មវិធីស្មើភាពនេះបានដែរ ឬ ទេ ?**

**ចម្លើយៈ** គ.ជ.ប មានសិទ្ធិបញ្ជាឱ្យផ្អាក ឬបញ្ឈប់ការផ្សព្វផ្សាយទាំងស្រុង ចំពោះកម្មវិធីស្មើភាពទាំងឡាយណាដែលមិនគោរពទៅតាមលក្ខខណ្ឌ ដូចដែលបានរៀបរាប់ខាងលើ ។(ប.ន ៧.១៣.១៥)

**សំណួរៈ** **ចុះបើក្នុងករណីមានគណបក្សនយោបាយណាមួយ បដិសេធការចូលរួមក្នុងកម្មវិធីដែលរៀបចំឡើងដោយអង្គការណាមួយ តើសាមីអង្គការពាក់ព័ន្ធនោះអាចដំណើរការកម្មវិធីរបស់ខ្លួនបានដែរ ឬ ទេ ?**

**ចម្លើយៈ** ក្នុងករណី គណបក្សនយោបាយណាមួយបដិសេធការចូលរួមក្នុងកម្មវិធី ដែលរៀបចំឡើងដោយអង្គការណាមួយ ឬមិនបានផ្ញើឯកសារដើម្បីផ្សព្វផ្សាយក្នុងកម្មវិធីនេះទេ សាមីអង្គការពាក់ព័ន្ធនោះអាចដំណើរការកម្មវិធីរបស់ខ្លួនបាន ដោយមិនប៉ះពាល់ដល់គោលការណ៍ស្មើភាពឡើយ ។(ប.ន ៧.១៣.១៦)